# TwkEPñkdMrI

The elephant's tears

NGET Sophoan

មេហ្វូងដំរីរៀបក្បួនជនូ ហៅកូនប្រពន្ធជួបជុំគ្នា
ខំទ្រាំជំងឺឈឺគ្រាំគ្រា យំថ្លែងពណ៌នាគ្រាកន្លង។

កាលបាននៅក្មេងវង្វេងដី ដើររកល្បាស់ខ្ចីធីស្មៅផង
អាយុដប់ឆ្នាំកម្មពៀរហោង លោកមនុស្សចាប់ចងឆ្លងដល់ស្រុក។

មនុស្សរាយអន្ទាក់លាក់ប្រកាំ ទាក់ជាប់ជើងស្ដាំនាំតត្រុក
បណ្ដើរបាទៅផ្លូវកាត់ថ្លុក លំពែងចាក់បុកចុកស្ទើរក្ស័យ។

ក្នុងរាជ្យព្រះបាទនរោត្ដម បាននៅភ្លៀវក្លំហំពេកក្រៃ
មនុស្សទាក់យកបានប្រាណស្ទើរក្ស័យ អាល័យជើងភ្នំភិរម្យរក្ស។

ចូលដល់បន្ទាយរាយពលពាន់ គេចោមជិះជាន់បង្អន់ធាក់
មានហ្វូងតូចធំផ្គុំទ្រមាក់ ប្រើផ្ទាក់ធ្វើបាបបង្ក្រាបបា។

គេផ្សាំងអោយឪត្រូវចេះខ្លាច ហ្មមានអំណាចកាចឫស្យា
កង្វេរពួថៅដៅក្បាលបា ដំបៅឈឺផ្សាវេទនាក្រៃ។

មនុស្សប្រើលុតលួនក្បួនព្យូហ៍សឹក ចេះថ្មឹកស្ទាត់ស្ទាញជំនាញជ័យ
ចេះស្ដាប់បញ្ជាគ្រាមានភ័យ អោយបាភ្លេចព្រៃពៃស្រុក។

អាយុម្ភៃឆ្នាំចាំមិនភ្លេច រូបបាចេះខ្មេចព្រេចបែនបុក
ទម្លាក់បំពង់ភ្នង់សម្រុក ដើរកាត់ទឹកថ្លុកស្រុកចំការ។

លុយទឹកលុយភក់ធ្នក់វាយខ្ទាំង ច្បាប់ក្បួនចម្បាំងរាំងបច្ចា
ខ្លួនសោតធាត់ធំហំហានក្លា ស្ដេចប្រោសមេត្តាតាំងនាមា។

«ឧត្ដមកុញ្ជរ» ល្អមានទ្រង់ សមវង្សពង្សពូជគជេន្ទ្រា
មេទ័ពប្រសប់កាន់យោធា យកជាជំនិះជិះធ្វើការ។

ដើរត្រួតបន្ទាយរាយគ្រប់ស្រុក គ្រប់ខេត្តសំបុកសំបូរខ្លា
ម្រឹកពៀរយង់ឃ្នងប៉ងប្រហារ ពេលឃើញរូបបាឆ្អេឆ្អារត់។

Egt.esaP&N
លោកកើតនៅថ្ងៃទី២១
ខែកុម្ភៈ ឆ្នាំ១៩៥៤
នៅភូមិព្រៃក្រឡា ឃុំទូកមាស
ស្រុកបន្ទាយមាស ខេត្តកំពត។
បច្ចុប្បន្នលោកជាមន្ត្រីមួយរូប
នៅមន្ទីរវប្បធម៌ និងវិចិត្រ
សិល្បៈ ខេត្តកំពត។ ស្នាដៃ
ដែលលោកធ្លាប់តែងនិពន្ធ
និងទទួលបានពានរង្វាន់មាន
ទាំងអស់ប្រាំបីស្នាដៃ។

ខ្លាខ្លាចឪពុកភ្លុកវែងស្រួច　　រោទិ៍ញ្ញត្រលួចញ័របពិត
ដំរីផងគ្នាភាល់អុត　　លំឪនក្បាលផុតរត់ចេញឆ្ងាយ។

មេទ័ពឈរស្កែតលើខ្នងបា　　បញ្ជាសេនារាល់រូបកាយ
ការពារព្រំដែនសែនសប្បាយ　　បង្ការអន្តរាយឆ្ងាយធានី។

ពលផងចោមរោមអង្អែលឪ　　ខ្លះបានអំពៅស្រូវអោយស៊ី
ឧត្តមកុញ្ជរល្អគ្មានពីរ　　អង់អាចពលីទីមរណៈ។

ជំនិះមេទ័ពគាប់ចិន្តា　　ភ្លេចមេភ្លេចបាព្រៃល្បាស់ល្បាក់
មេទ័ពថ្នមថៃស្នេហ៍ស្មោះស្ម័គ្រ　　ដប់ឆ្នាំសំណាក់ក្នុងខ្លោងព្បៀត។

បរិបូរណ៍ភោគផលស្កប់ស្កល់ពេក　　យប់ដេកថ្ងៃដើរប្រើឈ្លបឆ្លៀត
ស្រុកខ្មែររាជ្យនោះគ្រោះចង្អៀត　　បារាំងចូលជ្រៀតលេងស្មៀតថ្មី។

បង្ខំអោយហ្លួងឡាយព្រះហស្ថ　　អំណាចទាំងអស់ថ្លោះសេចក្តី
បារាំងកាន់កាប់ច្បាប់ទឹកដី　　រាស្ត្រខ្មែរប្រុសស្រីស្តីលែងចេញ។

ខ្មែរស្នេហាជាតិរវាតសុខ　　ចេញមុខជួយស្រុកបុកបណ្តេញ
ព្យាបាទបារាំងច្បាំងអោយចេញ　　ទុក្ខម្នោទោម្នេញពេញអប្រិយ៍។

គ្រានោះបារាំងតាំងប្រើខ្មែរ　　មេទ័ពប្ញកែថៃទឹកដី
អោយចេញបង្ក្រាបឧទ្ទាមថ្មី　　បរពលដំរីវាយប្រហារ។

គេជិះខ្នងឪកាត់ផ្លូវព្រៃ　　រំពឹងរំពៃស្ទាក់បច្ចា
ចៃដន្យមេទ័ពគាប់រាជការ　　ត្រូវព្រួញមរណាអសារបង់។

ធ្លាក់ពីខ្នងឪអាស្រូវក្រៃ　　ពួកព្រៃបានដៃវាយតម្រង់
ទ័ពបារាំងខ្មែរស្លាប់ក្រញង់　　រាល់រូបរាល់អង្គលែងចង់ច្បាំង។

បាក់ទ័ពទាហានលានប្រយុទ្ធ　　ភ្លើងពុំរលត់ដុតទីតាំង
រូបបាក៏បោលចោលចម្បាំង　　ចោលទ័ពបារាំងតាំងពួនព្រៃ។

ឈាមហូរដាបពោះព្រោះលំពែង　　រងទុក្ខចំបែងស្មើរក្សិណក្ស័យ
សម្ងំលាក់ខ្លួនពួនអាស្រ័យ　　ផុតរាជ្យក្សត្រថ្លៃនរោត្តម។

បាស្កាត់ដើររកហ្វូងដំរី　　រូបរួមមេត្រីថ្លែមនោរម្យ
ជួបវង្សត្រកូលប្រមូលជុំ　　រស់ក្នុងព្រៃភ្នំជីវំសុខ។

មានមេដំរីពិសីស្រស់ ដប់ក្បាលសមរស់សែនស្រណុក
ចោមរោមបំរើប្រើបញ្ចុក ចំណីចំណុកសុខម្លេះណា។

បង្កើតបានកូនមិនស្ងួនព្ធូជ ធំតូចចោមរោមជាបរិវារ
បានឡើងជាមេហ្វូងគុជសារ ត្រួតត្រាទឹកដីក្នុងព្រៃព្រឹក្ស។

ព្រះបាទស៊ីសុវត្ថិសុគតទៅ មុនីវង្សជាឪបុណ្យអធិក
តវង្សចក្រីត្រួតដីទឹក បានៅរលឹកនឹកឃើញអស់។

ព្រះសីហនុអំណាចស្តែង ស្តេចគ្រងដំណែងតែងប្រោសប្រស់
ប្រទានអភ័យសត្វព្រៃស្មោះ ហាមអស់ទាហានព្រានប្រមាញ់។

មិនអោយចាប់សត្វស្កាត់រកស៊ី កៀងកាល់ឈ្មោលញីលីធ្នូបាញ់
ព្រួញស្នាកាំភ្លើងគ្រឿងប្រមាញ់ ហ៊ានបាញ់ត្រូវទោសអូសដាក់គុក។

ចិតសិបឆ្នាំប្លាយកាយបាឯង បានកូនប្រលែងលេងផុតទុក្ខ
កើតបានទាំងចៅផៅឪពុក តគ្រុករកស៊ីទីឋានស្ងាត់។

រាប់ឃើញរយក្បាលត្រអាលចិត្ត កូនចៅអាណិតគិតប្រណិបត្តិ
ខ្លួនកាន់តែចាស់ប៉ះអត្តខាត់ ជំងឺតម្កាត់បាត់កម្លាំង។

ភ្លុកទាលធ្មេញរិលខ្ចិលទំពា ជរាចូលដល់កង្វល់ខ្លាំង
ទសវត្សចិតសិបស្រុកកើតច្បាំង យន្តហោះអាគាំងតាំងទម្លាក់។

គ្រាប់បេ៥២ស៊ីព្រៃភ្នំ រលើងរលំពុំរពាក់
ដុំថ្មប៉ើងខ្ទាតរវាតធ្លាក់ សត្វផងផ្អើលភ្ញាក់ធាក់គ្នាវរ។

គ្រានោះអំបែងគ្រាប់ពិឃាត វាខ្ទាតត្រូវបាកំពុងឈរ
ចំជើងដំណំគ្រាំស្ទើរមរ កូនចៅរីកវរត្រដរខ្យល់។

ស្រុតអស់ដប់ក្បាលកាលនោះឯង ទឹកភ្នែកចំបែងរែងខ្វាយខ្វល់
បាននាំកូនរត់ផុតអកុសល ចូលដល់ដីសៀមត្រៀមប្រយ័ត្ន។

ចាកចោលដីខ្មែរក្បែរមរណា លាព្រៃព្រឹក្សាការសម្ងាត់
លាក់ខ្លួនពួនរស់ព្រោះវិបត្តិ ស្រុកខ្មែរខ្វាយខ្វាត់បាត់សិរី។

ជម្លោះខ្មែរឯងប៉ែងផ្តួលគ្នា ដណ្តើមភារាប្រជាប្រិយ
កាំភ្លើងឆ្លើយឆ្លងរំពងដី ផ្អើលហ្វូងដំរីខ្ចីចោលស្រុក។

ទ្រាំនៅម្ដេចបានប្រាណជាសត្វ
រត់កាត់ទុតិមទ្រនំទុក្ខ
លាព្រៃកំណើតកើតជម្រុក
សំបុកទ្រយុកទុក្ខផ្ដន្ទា។

ខ្មែរច្បាំងក្នុងស្រុកកុកក្អែកផង
ត្រសងហើរហិចគេចអង្គា
ត្នាតស្ទាំងភ្លូវាំងភាំងភ័យា
ចោលដងអធ្វានភាល័យ។

ខ្លោងខ្លាក៏បោលចោលទ្រនំ
ទន្សោងព្រៃភ្នំយីរីងរៃ
មេបាបាត់កូនស្ងួនហប្ញទ័យ
ឆាប់ៗវៃៗលៃយាត្រា។

ចូលព្រៃសៀមអស់ចន្លោះធេង
សង្រេងដង្ហោយសោយសោកា
អាល័យព្រៃខ្មែរខ្សែដូនតា
កម្មកាចឫស្យាប្រហារបង់។

ព្រៃថៃសុខសប់ជាភ័ព្វពិត
ជីវិតរួចរស់ព្រោះមានសង្ឃ
សាសនាព្រះពុទ្ធវិសុទ្ធអង្គ
ហាមមនុស្សលះបង់ត្រង់បាណា។

ច្បាប់គេម៉ឹងម៉ាត់ស្កាត់មនុស្សខ្វូច
ព្រានព្រៃកំហូចលួចប្រហារ
មិនអោយបរបាញ់ប្រមាញ់ខ្លា
ដីរស្វានស្វាព្រឹក្សាសាន្ត។

ទើបយើងបានរស់ព្រោះច្បាប់គេ
តែចិត្តគ្នាន់គ្នេររេរំខាន
នឹកដល់ព្រៃខ្មែរក្បែរស្មសាន
ឳកូនធ្លាប់បានសម្រាន្តរម្យ។

ខ្មែរមានបឹងបួរអូររំលេច
ល្បាស់ព្រេចត្រួយខ្ចីនាព្រៃភ្នំ
យកជាចំណីធីធាត់ធំ
នឹកឃើញទ្រនំង៉ំឱរ៉ា។

ផ្ទះគេមិនដូចផ្ទះផងខ្លួន
ទ្រាំពួនម្ដៃឆ្នាំរកាំផ្សា
នឹកភ្នំឱរ៉ាល់អង្កាល់រ៉ា
បានជួបជីវ៉ាបុប្ផផាន។

ទសវត្សរ៍កៅសិបប្រឹបចូលដល់
ខ្មែររៀងរួបរាល់ស្គាល់ក្បែមក្សាន្ត
លើកគ្នាប្រជុំជំនុំបាន
ព្រមព្រៀងគ្រប់ប្រាណបានស៊ីញ៉េ។

ទម្លាក់អាវុធដុតវាចោល
កម្រោលឧត្បាតខាតខ្មែរទេ
ខ្លោចស្លាប់ឈាមដាបផ្ទៃទន្លេ
កុំគ្នេរទុកនៅត្រូវកំទេច។

ប្ដូរយកសន្តិភាពរៀបរដ្ឋា
ពិសិដ្ឋចិន្តាថ្លាដូចពេជ្រ
ស្ងប់ស្ងួរកាំភ្លើងធ្លាប់ប៉ើងខ្ទេច
ពន្លិចធ្លាក់ទៅផ្លូវអវិចី។

សង្គ្រាមស្ងប់ហើយស្បើយកាយា
នឹកដល់គុជសារបាដីរ
នាំកូននាំចៅទាន់ក្ដៅដី
វិលចូលបុរីព្រឹក្សព្រៃខ្មែរ។

ព្រាត់ជាងម្ភៃឆ្នាំកម្មវិរលស់
បានយល់ទ្រនំជំរឹស្នេហ៍
ឥឡូវស្បើយគ្រោះរស់បានល្ហែ
ទុក្ខផងប្រួលប្រែបែរមានន័យ។

ឱរ៉ាល់ទុគ៌មជ្រងំស្ងាត់
ព្រៃឈើជាទ្រព្យគាប់ហឫទ័យ
សម្បត្តិធម្មជាតិឃ្លាតផុតភ័យ
បានយល់មាសមេប្រពៃពិត។

នាំកូននាំចៅផៅសន្តាន
នឹកស្មានថាអស់បច្ចាមិត្រ
កំសាន្តរកស៊ីទីឆ្ងាយជិត
គំនិតសន្តិភាពដាបដល់ប្រាណ។

ព្រៃឈើវាលអស់ចន្លោះផេង
ចង់មានលឿនឆាប់កាប់ឈើបាន
ខ្មែរខ្លះវង្វេងកេងប្រមាណ
អារលក់ដូរឡានប្រាណលោភលន់។

ឱរ៉ាល់ភ្នំធំជុំមេត្រី
ទើបបាននាំផ្លូវទៅរួសរាន់
លួមហ្វូងជីរជ្រែកអាសន្ន
តំបន់ឆ្ងាយស្រុកសុខសម្រាន្ត។

ឧត្តមកុញ្ជររស់រងកម្ម
បាត់កូនម្ដងមួយព្រួយប្រមាណ
វ័យមួយរយឆ្នាំកម្មគ្មានក្សាន្ត
ទាំងចៅកល្យាណបានបាត់ទៅ។

កូនខ្លះសើរើដើរបែកហ្វូង
មនុស្សឆ្នក់ប្រមាញ់លបបាញ់ត្រូវ
ចេញទិសខាងត្បូងខ្វងទាំងផ្លូវ
ចោលខ្មោចស្អុយនៅអាស្រូវក្រៃ។

គេកាត់យកភ្លុកទុកសាច់ឆ្អឹង
ប្រហារកូនអញពេញភិសម័យ
ជាតិមនុស្សម្លឹងៗថ្លឹងយកថ្លៃ
កូនអើយមកក្ស័យដោយដៃខ្មែរ។

ខ្លះធ្វើទាហានមានអំណាច
បុណ្យបាបភ្លេចអស់រស់ព្រោះតែ
ឥតខ្លាចច្បាប់ក្បួនខ្លួនពូកែ
ដុល្លារស្រីស្នេហ៍ ឱ! ខ្មែរអើយ។

បានយល់សពកូនស្ងួនសម្លាញ់
ទឹកភ្នែកតក់ៗស្រក់មកហើយ
ក្ស័យព្រោះគេបាញ់បាឥតស្បើយ
កុញ្ជរព្រៃអើយអ្នកយាសយំ។

ទួញសោករណ្ដំក្រំឱរ៉ា
វ្ហូម! វ្ហូម! ស្រែកហៅកូនចៅជុំ
កើតក្ដីទោសានាទុគ៌ម
ទួញយំស្រណោះមិនអស់ចិត្ត។

ខ្លះកាច់ស្លឹកឈើគ្របលើសព
កើតកងគំនុំគុំអមិត្ត
ខ្លះឈូសដីកប់លុបមិនជិត
គួរគិតតាមដានប្រាណព្រានព្រៃ។

ទើបបាបញ្ជូនកូនទាំងឡាយ
ដើរក្រោយឯកឯងក្រែងមានភ័យ
ជៀសឆ្ងាយនៅខ្លួនពួនរំពៃ
បើឃើញព្រានព្រៃលៃដេញព្រេច។

សងសឹកអោយកូនស្ងួនកល្យាណ    បាស៊ូក្ស័យប្រាណខានរត់គេច
ហេតុកម្មអកុសលផ្តល់រំពេច    លោលេចក្បាលមនុស្សព្រួសគ្រាប់ភ្លើង។

ផាំងៗបីគ្រាប់ជាប់ៗគ្នា    អាស្សូរគជាចុកពើតពើង
គ្រាប់បៀមក្នុងពោះគ្រោះកាំភ្លើង    ទន់ជើងចង់ដួលរមួលក្តៅ។

ផ្អើលដល់កូនចៅហៅគ្នាស្រែ    ព្រានព្រៃភ្នែកសរត់លឿនស្លៅ
ឡើងកប់ចុងឈើលើដើមស្តៅ    ដីរខ្លាំងខ្លៅព្រេចម្តេចបាន។

មនុស្សមានបញ្ញានិងអាវុធ    តែចិត្តលាក់ពុតពន់ប្រមាណ
ហ្វូងសត្វក្តៅក្តួលរំជួលប្រាណ    ធ្វើមនុស្សពុំបានថ្កានជួបបា។

ឧត្តមកុញ្ជរឈរលែងនឹង    រំពឹងកូនចៅជួយជីតា
គ្រាហ៍ស្នួយនាំទៅផ្លូវព្រឹក្សា    ដល់ខ្នងបព្វតាមានជ្រោះជ្រៅ។

ចុកណាស់ចុកធន់ពន់ពេកពិត    ជីវិតគង់ស្រុតផុតលំនៅ
ទើបបាកំសត់មាត់ប្រដៅ    កូនចៅជួបជុំកុំយំអី។

ផ្តែផ្តាំរៀបរាប់រឿងអតីត    ព្រេងព្រឹទ្ធបាធ្លាប់ជួយដែនដី
ជំនិះមេទ័ពគួរគប្បី    អង្គព្រះចក្រីទ្រង់មេត្តា។

តាំងនាមកំណែនសែនសក្តិសម    ឧត្តមកុញ្ជរបវរា
ធ្លាប់ចូលវាយខ្មាំងច្បាំងបច្ចា    ថ្ងៃនេះរូបបាលាក្ស័ណក្ស័យ។

ចូរកូនកុំចងពៀរមនុស្សលោក    ឥតក្តីអធ្យោគអធ្យាស្រ័យ
កម្មកើតជាសត្វបាត់តំលៃ    ត្រូវដៃលោកមនុស្សរស់នឹងប្រាក់។

ស្រីស្រាល្បែងភ្នាល់ខ្វល់ខ្វះលុយ    ទុយមុយរកស្មៀតជ្រៀតបាញ់ស្នាក់
ចង់បានភ្លុកបាប្រាថ្នាជាក់    លបលាក់លង់ខ្លួនពួនព្រឹក្សា។

វ័យបាទើបបានមួយរយឆ្នាំ    ជាកម្មអកុសលដល់មរណា
ចូរកូនកុំសងសឹកមនុស្សា    កុំភ្លេចខេមរាណាកូនអើយ!

បើបាស្រុតទៅនៅកូនចៅ    រក្សាវង្សផៅកុំកន្តើយ
កុំចោលព្រៃខ្មែរធ្លាប់ល្វែល្វើយ    កូនអើយចូរចាំបណ្តាំបា។

ឯភ្លុកទាំងគូឪកាច់ទុក    នៅក្នុងគ្រលុកផែនសិលា
មិនអោយមនុស្សលោកយកឡើយណា    អោយហ្វូងគុជសារវរវន្ទា។

ផ្គាំស្រែចមិនបាច់បង្អង់យូរ បាស៊ូខិតខំទ្រាំរោគា
ក្រោកឈរកាច់ភ្លុកនឹងបាទា ឈាមក្រាលពសុធាវេទនាក្រៃ។

ប្រមោយកោយដាក់ទម្លាក់ទៅ ក្នុងរូងទុកនៅទាំងអាល័យ
ទឹកភ្នែកជន់ជោរហូរហៀបក្ស័យ សត្វថ្លៃរេរាវាររកផ្លូវ។

ទម្លាក់ខ្លួនចុះក្នុងជ្រោះជ្រៅ លាផុតលំនៅចាកឆ្ងាយទៅ
បាត់រូបបាត់ប្រាណខានឃើញនៅ អាសូរកូនពៅនៅបោដោះ។

វាស្រែករូមៗយំឱបមេ ស្តាយបាម៉្លេះទេគ្នេរស្រណោះ
ឱ! លោកមនុស្សអើយឥតអាឡោះ ម្តេចឡើយមកគោះកែប្រហារ។

ទឹកភ្នែកដីរីព្រៃល្បាស់ល្បាក់ សស្រាក់សស្រោកជោគភក្ត្រា
អង្វរទ្ទូញយំសុំករុណា លោកឈប់ប្រហារណាមនុស្សអើយ។